# *ក្រមសីលធម៌របស់សមាជិក សមាជិកា គណបក្សប្រជាធិបតេយ្យមូលដ្ឋាន*

ដើម្បីចូលរួមចំណែកក្នុងវិស័យនយោបាយ និងសង្គមឲ្យមានប្រសិទ្ធភាព ក្នុងគោលបំណងដោះស្រាយបញ្ហាជាតិ និងសង្គមប្រកបដោយគតិបណ្ឌិតក្នុងស្មារតី "សាមគ្គីភាព យុត្តិធម៌ អហិង្សា" ក៏ដូចជាពង្រឹងលទ្ធិប្រជាធិបតេយ្យ និងលើកកំពស់សីលធម៌សង្គម សមាជិក សមាជិកា **គ ប ម** ទាំងអស់ត្រូវគោរពក្រមសីលធម៌ដូចតទៅ៖

១) គោរពគុណតំលៃ និងគោលការណ៍របស់ **គ ប ម**។

២) ធ្វើតែអំពើល្អ (កាយ វាចា ចិត្ត) ផ្តល់ភាពជាគំរូល្អ ក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និងសង្គម។

៣) មិនប្រព្រឹត្តអំពើពុករលួយ បក្សពួក និងគ្រួសារនិយម ដោយតម្កល់ផលប្រយោជន៍សាធារណៈ និងជាតិជាធំ។

៤) មិនប្រើភាសាជេរប្រមាថ ម៉ាក់ងាយ និងលាបពណ៌ ជាពិសេសចំពោះអ្នកមិនគាំទ្រ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន។ ផ្តល់ការរិះគន់បែបស្ថាបនាលើបញ្ហាប្រឈមផ្សេងៗ។

៥) ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។

៦) យល់ទុក្ខធុរៈ និងចេះជួយអ្នកទន់ខ្សោយ និងអ្នកងាយរងគ្រោះ។

៧) ឧស្សាហ៍ព្យាយាម សន្សំសំចៃ ម៉ឺងម៉ាត់ម៉ត់ចត់។

៨) ខិតខំរៀនសូត្របង្កើនសមត្ថភាពរបស់ខ្លួនជានិច្ច ដើម្បីជួយគ្រួសារ សហគមន៍ និងជាតិ។

សមាជិក សមាជិកា ដែលគោរព និងអនុវត្តក្រមសីលធម៌បានល្អ នឹងទទួលបានការសរសើរលើកទឹកចិត្ត ដោយឡែកសមាជិក សមាជិកា ណាម្នាក់ជាពិសេសសមាជិក សមាជិកាក្នុងរចនាសម្ព័ន្ធដឹកនាំគ្រប់កំរិត និងសមាជិកជំហរដែលមិនគោរពក្រមសីលធម៌ដូចមានចែងខាងលើ អាចនឹងត្រូវទទួលការដាក់ពិន័យពី **គ ប ម**។

អនុម័តដោយគណៈកម្មការបណ្តោះអាសន្ន ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៥